# វិបត្តិសង្គមជាតិ ក្នុងសម័យជាប់ភ្លើង

ក្នុងឆ្នាំ ១៩៤៥ ជាពិសេសចាប់តាំងពីថ្ងៃទី ៩ មីនា ទៅដល់ដើមឆ្នាំ ១៩៤៦ ស្ថានភាពនៅឧបទ្វីបឥណ្ឌូចិនទាំងមូលមានការប្រែប្រួលក្រឡាប់ចាក់សំប៉ើមណាស់ ។ ទ័ពអាណានិគមបារាំងចាញ់ជប៉ុន ត្រូវជប៉ុនចាប់ជាឈ្លើយ ។ អ្នករដ្ឋការ ជាពិសេសរាប់ទាំងកងទ័ព និងអ្នកបំរើផលប្រយោជន៍បារាំងក៏ត្រូវជប៉ុនចាប់ដាក់គុកខ្លះ ឬ ធ្វើបាប ។ លុះមកដល់ដើមឆ្នាំ ១៩៤៦ ទ័ពសម្ព័ន្ធមិត្តឈ្នះជប៉ុនម្ដងវិញ ភាពក្រឡាប់ចាក់ក៏មានឡើងទៀត ។ អ្នកដែលមានការទាក់ទងជាមួយជប៉ុន នោះទាល់ផ្លូវនយោបាយ ក៏ដូចក្នុងវិស័យឯទៀត ព្រមទាំងអ្នកស្នេហាជាតិខ្លះទៀតត្រូវទទួលបាបគ្រោះពីបារាំងវិញម្ដង ។

ប៉ុន្តែអ្វីដែលជាប្រភពនៃវិនាសកម្ម តាំងពីជំនាន់នោះរហូតមកសព្វថ្ងៃ គឺចលនានៃយួនវៀតមិញ ។ ចលនា

គស្ទីរបស់ជនជាតិយៀកណាម ចំពោះអាណានិគមបារាំង នោះ ពិតមែនតែមានកើតឡើងតាំងពីយូរយារណាស់មក ហើយក្តី ក៏ចលនានេះទើបតែនឹងមានបញ្ចេញសកម្មភាព ខ្លាំងឡើង ៗ ចាប់តាំងពីមានការប្រែប្រួលដូចជម្រាប ខាងលើ ៗ ·

ដូចហេតុនេះហើយ បានជាក្រោយពីបារាំងចាញ់ជប៉ុនទៅ ពលរដ្ឋយួន ត្រូវធ្វើការហ្វឹកហ្វឺនវិជ្ជាយុទ្ធសាស្ត្រនៅគ្រប់ត្រកល្អក ពោលគឺដូចជានៅក្នុងភូមិព្រៃកគយ ស្រុកអណ្តូងទឹក ខេត្តយូរាំង ៗ ចលនាយៀកមិញត្រូវរីកធំធាត់ឡើង ហើយ ការហ្វឹកហ្វឺនរបស់គេ ក៏កាន់តែមានសន្ទុះស្ទុះឡើងជាលំដាប់ ៗ ក្រោយពីយួននិងយួនបង្ហាត់គ្នាគេមក បងប្អូន ខ្មែរយើងនៅទីនោះ ក៏ដូចជានៅទីដទៃទៀតដែរ ក៏ត្រូវ បង្ខំចិត្តចូលហ្វឹកហ្វឺនវិជ្ជាយុទ្ធសាស្ត្រនឹងគេដែរ ៗ

ចាប់ពីដំបូងដែលមក ខ្មែរយើងនេះតែមានពិភាល់ចំពោះ ចិត្តថ្មើមរបស់បងប្អូនយួនមកលើយើង ដែលនាំឲ្យយើង ខ្វះការគក់ក្តៅ ហើយដណ្តឹងសួរខ្លួនឯងថា តើការប្រមូល គ្នាមក ថាមកហ្វឹកហ្វឺននេះដើម្បីគេប្រមូលយើងមកក្រុង ទុក មិនឲ្យយើងចេញទៅណាឆ្ងាយ រកទទួលទានដូចធម្មតា ឬ បានជាមានការពិភាល់ដូចនេះ ពីព្រោះក្នុងការហ្វឹកហាត់ គេគ្មានបង្រៀនអ្វីក្រៅពីរៀនដើរ ៗ ក្រោយមកហេតុ

គិតកំបាំងលេចចេញម្ដងបន្តិចៗ ដែលជាកត្តាមួយជំរុញ ឲ្យខ្មែរមានការត្រិះរិះ:

១–មុនដំបូងគេហាមមិនឲ្យកាន់ កាំបិត -ដាវ-ស្នូ-លំពែង-ក្រពត់ ដែលមុតមាន នោះជាឧបករណ៍សំរាប់ធ្វើស្រែក៏ដោយ ។ ក្រោយមកមានកន្លងខ្លះ គេដើរប្រមូលយករបស់ទាំងនោះតែម្តង ហើយគេទុកតែកាំបិតធ្វើគ្រឿងមួយប្រើប៉ុណ្ណោះ ។

២–ពេលបាក់ដើរលក់ដូរ ខ្មែរនិងយួនតែងលេងសើចដាក់គ្នា កើតជាជេរប្រមាថគ្នា ឬដាល់តប់គ្នា ក៏ព្រោះតែពាក្យជេរប្រមាថរបស់គេ ៗ ច្រើនតែជេរខ្មែរថាចោរនេះ ចោរនោះ ឬ ចោរជាគេថា ខ្មែរឲ្យធ្វើមេក្លូមិនចង់ជំនួសផងជាដើម ឬ ក៏គេថា « យួនស្គាល់ប្រពៃណីខ្មែរមកពីនេះដើម » ។

៣–ម្យ៉ាងផងនេះទៀត ពេលបាក់រៀនផ្លូវៗ ច្រើនតែបញ្ចប់ដោយការវាយតប់គ្នា ក៏ព្រោះខាងយួន ពេលគេបាក់ដើរយកចង្កឹះនិងចង្កូនយ៉ើង គេច្រើនលើកដើមដាក់ខ្មែរពីចម្ងាយ ដោយឡែក យកចង្ហាក់ដើរមួយពីរនោះតែម្តង ។

៤–ជួនកាលពេលបាក់រៀនរួចមានតែកំបិល ដែលសល់អំពីជំនាន់ដើម គេស៊ីទុកចោល គេគត

*ឲ្យខ្មែរទេ បើគេឲ្យ គេទុកឲ្យគ្នាគេយកបានស្រេចចាច់សិន បើសល់ទើបបានមកបងប្អូនយើង ។*

*៥—ក្រៅពីកម្ពុជាសឹងឡាស់ឡាស់ដូចនេះ ទើបមានការសង្ស័យទៅលើបណ្ដាជនច្រើនខ្លះទៀត ដូចការប្រជុំ គេច្រើនប្រជុំតែជាមួយគ្នាគេ ហើយក្រោយពីការប្រជុំម្ដង ៗ តែងមានហេតុភេទផ្សេងៗទៀតកើតឡើង ដូចជាគេចែកផ្ទះខ្មែរ មានចែកផ្ទះចិនដោយ ជាក់ រុករើកក្ដូបកកាយ ដោយគេថា រកកាំភ្លើងដៃជាដើម ។*

ចំពោះព្រឹត្តិហេតុដូចនេះ យើងតែងតែពិគ្រោះគ្នា ពីព្រោះយើងមានគំនិតមួយជាប់ជានិច្ច គឺយើងមិនព្រមស្លាប់ដោយសារគេខ្ទប់ដង្ហើមយើងជាដាច់ខាត ហើយយើងស្រុះស្រួលគ្នាធ្វើបានសម្រេចដូចតទៅនេះ៖

*១—រកលេសបំបែកការហ្វឹកហ្វឺនចេញពីយួន យើងធ្វើយ៉ាងនេះ ព្រោះយើងត្រូវរៀនវិជ្ជាយុទ្ធសាស្ត្រថែម ៗ ការរៀននេះយើងមិនត្រូវការហាត់ទៀតទេ មិនតែប៉ុណ្ណោះ យើងមានគ្នាយើងជាអ្នកចេះវិជ្ជាយុទ្ធសាស្ត្របរិបូណ៌ មានកលល្បិចចីពធ្នក់ជាស្រេច យើងលួចបង្រៀនគុនដាវ - គុនដំបងបន្ថែម ព្រោះបងប្អូនយើងខ្លះមានការជំនាញស្រាប់*

យប់ឡើងត្រូវសមយុទ្ធពីរបៀបការពារភូមិ ពីរបៀប ចូលប្រយុទ្ធ ជាពិសេសទៅទៀតយើងត្រូវការពារស់ ស្នាក់ខ្មែរ ។ ឲ្យមានមនសិការជាតិ ដោយយើង ល្អបរៀនប្រៀននគរាជ និងសុវណ្ណភូមិ ។ ត្រៀមពីបទពីរនេះយើងសកចេះអ្វីទៀតទេ គួរឲ្យ ស្តាយ ។

២–យើងរៀបចំអាវុធរបស់យើង ដូចជាដាវ កាប់ស្មៅ មានកាំបិត ដែលយើងទំលាក់ចុក យើងចាប់លាវាឲ្យគ្រងវិញ កាំបិតចុងស្រួចដែរ ដែកដងខ្លី យើងផ្លាស់ដាក់ដងវែង ប្រវែងមួយម៉ែត្រ កន្លះ ល្មមប្រើការក្នុងពេលប្រយុទ្ធ យុវជនគេមាន កាំបិតស្នៀតគ្រប់ស្ពាសម្រាប់ចូលប្រឡូក ។

៣–យើងរៀបចំកន្លែងសម្រាប់លាក់ស្បូវតាម ក្រោមផ្ទះនិងជីកកប់តាមការវាលស្រែ ឬក្រោម ផ្ទះសម្រាប់លាក់របស់ដូចជា ចាន- ឆ្នាំង- ចាន - ប្រាក់- អាវ- ខោ ។ល។

៤–យើងបានដើរតាមអ្នកមានទោចក្រយានទុក សំរាប់ប្រើការ ក្នុងការទាក់ទងរបស់យើងក្នុងពេល មានអាសន្ន និងទោចក្រយានណាចាស់ៗគេលែង ប្រើការ ទុកសម្រាប់អោយគេបំពាក់ធ្វើកាំភ្លើងដង ។

វិធានការដែលរៀបរាប់មកនេះ យើងពុំមានបំណងអ្វីទៅធ្វើការឈ្លានពានជាតិសាសន៍ណាទេ ប៉ុន្តែយើងគ្រាន់តែធ្វើក្រាប់សត្រូវដេរវៃប៉ុណ្ណោះ ពីព្រោះតាំងពីណាពីណាមក បងប្អូនខ្មែរ និងបងប្អូនយួនតែងរាប់រកគ្នា ខ្មែរនិងយួនមានចំណងមិត្តភាពជាមួយគ្នា ដែលភាសាជនបទស្រុកនោះគេហៅថា ក្មើ ៗ ពេលចូលឆ្នាំយួន-ចិន និងចូលឆ្នាំខ្មែរ មានការអញ្ជើញគ្នាទៅមក មានយួនភាគមិនតិចទៅដែលជឿបុណ្យ ជឿបាបដូចយើងដែរ ៗ ការដែលគេប្រែអាកប្បកិរិយាកាយវិការគេ នៅគ្រាចុងក្រោយនេះ យើងមិនទាន់ច្បាស់ថា គេមានបំណងយ៉ាងណាមកលើយើងទេ ប៉ុន្តែយើងបានប្តេជ្ញាចិត្តជាស្រេចហើយថា យើងស្លូតមែនតែយើងមិនព្រមស្លាប់ជាដាច់ខាត ៗ

ថ្ងៃ ៗ ក៏ចេះតែកន្លងទៅ ព្រឹត្តិការណ៍ជាច្រើនក៏យើងបានឆ្លងកាត់ ប៉ុន្តែថ្ងៃមួយយើងភ្ញាក់នឹងពត៌មានដែលលេចចេញមកពីអ្នកនេសាទ ៗ អ្នកនោះបានប្រាប់បងប្អូនយើងឱ្យប្រុងប្រយ័ត្ន ពីព្រោះយួននៅខេត្តព្រះត្រពាំង ក្នុងភូមិសម្តេចចាប់ធ្វើបាបខ្មែរ ដោយគេបាននាំគ្នាកៀងចាប់យកក្របីបងប្អូនយើងរាប់រយក្បាលត្រង់ៗតែម្តង ម្ល៉ោះហើយមានការកាប់សម្លាប់គ្នាយ៉ាងសាហាវ ៗ អ្នកនាំពាក្យមិនបានបញ្ជាក់

អ្វីក្រៅពីនេះទេ ពីព្រោះយើងមិនបានជួបផ្ទាល់ ៗ យើងក៏
បាក់ត្អូញឱ្យដំណឹងដល់បងប្អូនយើងភ្លាម ដើម្បីការពារខ្លួន
ប៉ុន្តែសុំកុំឱ្យមានប្រតិកម្មអ្វីឱ្យសោះៗ យើងបានប្រាប់ដល់ភូមិ
ផ្អាគានារ - កំពង់ឈើទាល - ជង់ក្តាន់ - បឹងព្រលិត - ភូន
ព្រែក ដើមពោធិ៍ អណ្តូងទឹក ទួលតាង-ផ្អាហៀងជូដាន់ -
ដៃខង ផ្គាំពេន ព្រែកចាក ផ្អាឯលិច ផ្អាឯកើត ផ្អា
មាន់គោង ដែលសុទ្ធតែភូមិស្លុតស្លូត មានខ្មែរនៅយ៉ាងកុះ
ករ ឱ្យប្រុងប្រយ័ត្នតែដោយស្ងៀមស្ងាត់ គឺឱ្យ «ដាំដើមគ
មុខផ្ទះទាំងអស់គ្នា» ៗ អ្នកនៅមាត់ព្រែកជាប់ទីងសមុទ្រ ត្រូវ
បាក់ការឱ្យយាម ដើម្បីពិនិត្យខ្ទកក្តោងចេញ-ចូល ៗ

ប៉ុន្មានថ្ងៃក្រោយមកយើងមានការរន្ធត់ជាខ្លាំង ដោយ
ការពិភាល់របស់យើង បានលេចដារូបរាងឲ្យរស់
ក្រៅឡើតគឺនៅក្នុងភូមិកោះប្រហាគ - យ៉ាវាំយ - ផ្អាអណ្តូគ-
ដាំគិន - ដាំយើយ-ព្រែកហ្សុរផុង ឈ្មោះភូមិ ៣ ខាងក្រោយ
នេះគ្នាឈ្មោះដាំខ្មែរទក្នុងទេក្តកលលរ យួនបានបញ្ឆោត
បងប្អូនយើងប្រុសៗ ចាយករទៅទទួលស្វាគមន៍ «លោក
ធំ» មួយដើម្បីហ៊ឺកហ៊ឺន ហើយបញ្ចូលក្នុងរោងដាក់ស្រា
របស់ជប៉ុន ផុតសម្លាប់ទាំងរស់ ចំនួនច្រើននាក់ «ត្រាន់
តែអ្នកភូមិផ្អាអណ្តូគមួយមានផុតស្លាប់ ៤០នាក់» ៗ

ថ្ងៃបន្ទាប់មកទៀត ៖ បិនទៅផ្សារព្រែកគយ ដែលធ្លាប់

មានការទាក់ទងក្នុងមុខរបររកស៊ីជាមួយយើង បានល្អ ទើបឲ្យដឹងថា យួនវាប្រឹងបំផ្លាញវត្តគោកព្រៃក្យវោលដោយ ថាវត្តនេះខ្មែរតែងយកធ្វើជាកន្លែងប្រមូលផ្តុំ ៗ តាមគំរោងការសម្ងាត់របស់វា វាមិនមែនដុតវត្តដោយចំពោះទេ តែវាដុតផ្សារដែលនៅជាប់គ្នានឹងកុដិ សាលាទានដែលសង់ក្នុងវត្តនេះ ដើម្បីចម្លងភ្លើងក្នុងវត្ត ៗ

សូមជំរាបបញ្ជាក់អស់លោកអ្នកអានថា តាំងពីដើមទីរហូតដល់ពេលនេះ យើងមិនបានចាំថ្ងៃ-ខែទេ ព្រោះតែស្ថានភាពបន្ទាន់យើងកាលនោះ ប្រៀបបានទៅនឹងទូកកណ្ដាលទន្លេព្រោះម៉ែ ឪនៅឯភ្នំពេញ ឥតបានដឹងទុក្ខរបស់កូនចៅនៅឯនោះសោះ ៗ បានវីង ឬ ជុំចុំមែនដែលហោចណាស់ គឺអាចបានជាអាផ្ទាកណ្ដាលផែរនោះ យោងតែខ្លួនឯងមិនរួចទៅហើយ តើមានគំនិតឯណាចាំដឹង ថ្ងៃ-ខែទៅកើត ៗ ម្យ៉ាងទៀត ព្រឹត្តិការណ៍អស់នេះកន្លងទៅអស់រយៈពេល ៦៦ ឆ្នាំទៅហើយ គឺចាប់តាំងពីខែធ្នូ ១៩៤៥ ដល់ ដើមឆ្នាំ ១៩៤៦ ម្ល៉េះ ៗ

មកដល់ពេលនេះយើងមិនទាន់ឃើញមានព្រឹត្តិការណ៍អ្វីចេញជារូបរាងនៅឡើយទេ នៅស្រុកព្រែកគយ ៗ ប៉ុន្តែការហ៊ឹកហ៊ឺនទាហានយួន ដូចជាភ្លើលជាងមុនតា ដែល ជាហេតុមួយនាំឲ្យយើងព្រឺព្រួចខ្លាំងឡើង ៗ ៗ